SINGAPORE BUSINESS FEDERATION
Apex Business Chamber

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

EMBASSY OF THE REPUBLIC OF SINGAPORE
PHNOM PENH

# សេចក្តីប្រកាសព័ត៌មាន

## “ស្វែងយល់ពីកម្ពុជា៖ ការយល់ដឹងពីកាលានុវត្តភាពធុរកិច្ចនៅកម្ពុជា”

នៅរសៀលថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) និងសហព័ន្ធធុរកិច្ចសិង្ហបុរី (SBF) ដោយមានការគាំទ្រពីស្ថានទូតសិង្ហបុរីប្រចាំនៅកម្ពុជា និងស្ថានទូតកម្ពុជាប្រចាំនៅសិង្ហបុរី បានរៀបចំសិក្ខាសាលា“ស្វែងយល់ពីកម្ពុជា÷ ការយល់ដឹងពីកាលានុវត្តភាពធុរកិច្ចនៅកម្ពុជា” តាមរយៈប្រព័ន្ធវីដេអូ ដោយមានការចូលរួមពីឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការ ក.អ.ក. លោកជំទាវ **គែម ឡាយឆេង** ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅកម្ពុជា និងឯកឧត្តម **សុខ ទឿន** ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសិង្ហបុរី។ សិក្ខាសាលាតាមប្រព័ន្ធវីដេអូនេះក៏មានការចូលរួមពីតំណាងសហព័ន្ធធុរកិច្ចសិង្ហបុរី និងតំណាងសភាពាណិជ្ជកម្មកម្ពុជា សរុបចំនួនប្រមាណ១៥០រូប។

ឯកឧត្តម **សុខ ទឿន** ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅសិង្ហបុរី បានរំលេចនៅក្នុងសុន្ទរកថារបស់ឯកឧត្តមថា **យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣** ដែលបានដាក់ចេញនៅដើមឆ្នាំ២០២១ មានគោលបំណងជំរុញពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងវប្បធម៌ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងលើកកម្ពស់កម្ពុជានៅក្នុងឆាកតំបន់ និងអន្តរជាតិ។ មន្ត្រីការទូតកម្ពុជាបាននិងបំពេញការងារ និងពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការជំរុញ និងអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ធ្វើយ៉ាងណាទាក់ទាញការវិនិយោគ និងភ្ញៀវទេសចរមកកម្ពុជាឱ្យកាន់តែច្រើនថែមទៀត។

នៅក្នុងសុន្ទរកថាបើក លោកជំទាវ **គែម ឡាយឆេង** ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅកម្ពុជា បានថ្លែងថា សិង្ហបុរីស្ថិតក្នុងចំណោមវិនិយោគិនបរទេសធំជាងគេទាំង៥ របស់កម្ពុជា។ ការវិនិយោគគ្របដណ្តប់វិស័យនានាដូចជា អចលនទ្រព្យ, ថាមពល,  ពាណិជ្ជកម្មនិងចែកចាយ, ម្ហូបអាហារ/អ្នកប្រើប្រាស់, ការអប់រំ

និងហិរញ្ញវត្ថុ។ ប្រទេសទាំងពីរមានការតភ្ជាប់ជើងហោះហើរចំនួន ៣៥ជើង ក្នុងមួយសប្ដាហ៍។ លោកជំទាវឯកអគ្គរដ្ឋទូតក៏បានបន្ថែមទៀតថា កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេនៅអាស៊ី។ កម្ពុជាបានងើបចេញពីជំងឺរាតត្បាតកូវីដ-១៩ បន្ទាប់ពីបានសម្រេចដោយជោគជ័យនូវយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ហើយត្រូវបានរំពឹងថានឹងមានកំណើនសេដ្ឋកិច្ចដែលមានកម្រិតខ្ពស់ដូចមុន។

ក្នុងសុន្ទរកថាគន្លឹះ ឯកឧត្តម **សុខ ចិន្ដាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការ ក.អ.ក. បានថ្លែងអំណរគុណដល់វិនិយោគិន និងធុរជនសិង្ហបុរីដែលបានជ្រើសយកកម្ពុជាក្នុងការបណ្ដាក់ទុនទាំងពេលកន្លងមក។ ឯកឧត្តមបានបន្ថែមថា បរិស្ថានវិនិយោគនៅកម្ពុជាដែលមានភាពអំណោយផល គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់រង់ចាំទទួលការវិនិយោគរបស់សិង្ហបុរី ដើម្បីច្បាមយកនូវកាលានុវត្តភាពដ៏លើសលុបក្នុងវិស័យកសិ-ចំណីអាហារ, សេវាកម្ម និងកម្មន្តសាល ។ ឯកឧត្តមរដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមពីតួនាទីសំខាន់របស់ការវិនិយោគសិង្ហបុរីនៅកម្ពុជា និងអំពាវនាវឱ្យមានការវិនិយោគកាន់តែច្រើនថែមទៀតពីវិនិយោគិនសក្ដានុពលសិង្ហបុរី ដែលនឹងរួមចំណែកដល់ការស្ដារឡើងវិញ និងអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាបានយ៉ាងឆាប់រហ័ស។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានសង្កត់ធ្ងន់ផងដែរអំពីសារៈសំខាន់នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីខែតុលា ឆ្នាំ២០២១ កន្លងទៅដែលផ្ដល់ការលើកទឹកចិត្តដល់វិនិយោគិនដែលអនុវត្តអភិក្រមប្រតិបត្តិធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងបរិយាប័ន្នក្នុងការវិនិយោគ និងធុរកិច្ចប្រចាំថ្ងៃរបស់ខ្លួន។

សិក្ខាសាលានេះ ត្រូវបានរៀបចំ ឡើងក្រោមឆ័ត្រនៃថ្នាល FYIstival របស់សហព័ន្ធធុរកិច្ចសិង្ហបុរី។ បន្ទាប់ពីសិក្ខាសាលានេះ SBF នឹងសម្របសម្រួលកិច្ចប្រជុំផ្គូផ្គងធុរកិច្ចរវាងអ្នកចូលរួម និងភាគីន ដែលជាសកម្មភាពតាមដានមួយដើម្បីពិភាក្សាបន្ថែមពីការចាប់អារម្មណ៍របស់ធុរជនសិង្ហបុរីនៅកម្ពុជា។

សិក្ខាសាលានាពេលនេះក៏មានការធ្វើបទបង្ហាញពីលោក **ជេវីដ ថតតិន** នាយកគ្រប់គ្រងក្រុមហ៊ុន Emerging Markets Consulting, លោក **ហាន់ ប៉េងក្វាង** នាយកប្រតិបត្តិធនាគារ Wing Bank (Cambodia), និងលោក **វិចឆាត សៅ** ប្រធានផ្នែកផ្សព្វផ្សាយក្រុមហ៊ុន Lim Siang Huat។

គួរបញ្ជាក់ថា គិតត្រឹមខែមិថុនា ឆ្នាំ២០២២ គម្រោងវិនិយោគរបស់សិង្ហបុរីដែលបានអនុម័តដោយ ក.អ.ក. និងកំពុងមានប្រតិបត្តិការមានចំនួន ១២៧ គម្រោង ក្នុងវិស័យទេសចរណ៍ កម្មន្តសាល ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យផ្សេងទៀត ក្នុងទឹកប្រាក់សរុបប្រមាណ ១,៥៣ ប៊ីលានដុល្លារអាមេរិក។

**ព័ត៌មានពីសាវតាររបស់សហព័ន្ធធុរកិច្ចសិង្ហបុរី, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, និង FYIstival**

**សហព័ន្ធធុរកិច្ចសិង្ហបុរី**

ជាសភាធុរកិច្ចកំពូល, និងជាស្ថាប័នឈានមុខគេក្នុងការ គាំទ្រផលប្រយោជន៍សហគមន៍ធុរកិច្ចនៅសិង្ហបុរីលើផ្នែកពាណិជ្ជកម្ម វិនិយោគ និងទំនាក់ទំនងឧស្សាហកម្ម ។ ក្នុងកម្រិតជាតិ SBF ធ្វើសកម្មភាពជាស្ពានតភ្ជាប់រវាងរដ្ឋាភិបាលនិងធុរកិច្ចនៅសិង្ហបុរីដើម្បីបង្កើតបរិស្ថានធុរកិច្ចប្រកបដោយភាពអំណោយផល។ ក្នុងកម្រិតអន្តរជាតិ SBF តំណាងសហគមន៍ធុរកិច្ចក្នុងវេទិកាទ្វេភាគី, តំបន់ និងពហុភាគី ក្នុងគោលបំណងពង្រីកបណ្ដាញពាណិជ្ជកម្ម និងធុរកិច្ច។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល÷ www.sbf.org.sg

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា (ក.អ.ក.) ជាស្ថាប័នប្រតិបត្តិដែលបំពេញមុខងារជាសេនាធិការ និងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេស។ ក.អ.ក. មានសមត្ថកិច្ចក្នុងការទាក់ទាញ និងការសម្រួលវិនិយោគបរទេសចូលមកកម្ពុជា។ វិនិយោគិនអាចស្វែងរកព័ត៌មានអំពីការវិនិយោគនៅកម្ពុជា ពាក់ព័ន្ធនឹងកាលានុវត្តន៍ភាពវិនិយោគ វិស័យអាទិភាព ការលើកទឹកចិត្ត ការធានាវិនិយោគ

ច្បាប់និងបទប្បញ្ញត្តិស្តីពីវិនិយោគ គម្រោងវិនិយោគ និងព័ត៌មានចាំបាច់ដទៃទៀតសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួន។

វិនិយោគិនអាចស្វែងរកព័ត៌មានអំពីការទូតសេដ្ឋកិច្ចរបស់កម្ពុជា ការធ្វើធុរកិច្ចនៅកម្ពុជា ការស្នើសុំទិដ្ឋាការអេឡិកត្រូនិក ទំនាក់ទំនងការទូតរវាងកម្ពុជា-សិង្ហបុរី ក៏ដូចជាទំនាក់ទំនងពាណិជ្ជកម្មនិងវិនិយោគពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសិង្ហបុរី។

FYIstival

ដាក់ឱ្យដំណើរការនៅខែសីហា ឆ្នាំ២០២០ ដើម្បីជម្នះការរឹតត្បិតនៃការវិវត្តន៍របស់ធុរកិច្ចក្រៅប្រទេសក្នុងអំឡុងការរាតត្បាតនៃជំងឺកូវីដ-១៩។ FYIstival គឺជាថ្នាលឌីជីថលចម្បងរបស់ SBF ដោយបានរចនាឡើងសម្រាប់ចែករំលែកព័ត៌មានទីផ្សារក្រៅប្រទេស និងរៀបចំទំនាក់ទំនងសម្រាប់ក្រុមហ៊ុន ធ្វើអន្តរជាតូបនីយកម្ម។ តាមរយៈថ្នាល FYIstival នេះ SBF មានបំណងធ្វើឱ្យប្រសើរឡើងនូវកំណើននៃសហគមន៍ឌីជីថលអន្តរជាតិ ដែលធុរកិច្ច សិង្ហបុរីអាចចូលរួម ទាក់ទងជាមួយធុរកិច្ចនៅក្នុងតំបន់ និងពង្រីកដែនអន្តរជាតូបនីយកម្មរបស់ខ្លួន។